ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ក្រសួងអប់រំ យុវជន និងកីឡា

លេខ ១០៣៤ ...........អបស.អយក

# ប្រកាសរួម
# ស្តីពី
# ការជ្រើសរើស ឬ ការប្រឡងចូលរៀន និងការប្រឡងបញ្ចប់ការសិក្សា កម្រិតបរិញ្ញាបត្ររង នៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល

***

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ-បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ-បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់ គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បកចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ-បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ ៤

# សម្រេច

**ប្រការ ១.-** ចំនួននិស្សិតដែលចូលរៀនថ្នាក់បរិញ្ញាបត្ររង នៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅពេលដែលពុំទាន់មានការប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិ។

**ប្រការ ២.-** ការជ្រើសរើសនិស្សិត ឬ ការប្រឡងចូលរៀនថ្នាក់បរិញ្ញាបត្ររង នៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល អាចប្រព្រឹត្តទៅបានតែមួយដងគត់ក្នុងមួយឆ្នាំសិក្សា ដោយមានការចូលរួមពីតំណាងក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា នៅពេលដែលពុំទាន់មានការប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិ។

**ប្រការ ៣.-** ការជ្រើសរើស ឬ ការប្រឡងចូលរៀន ព្រមទាំងការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង នៅគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលត្រូវមានការចូលរួមពីតំណាងក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងទាំងពីរត្រូវធ្វើការណែនាំអំពីយន្តការជ្រើសរើស ឬ ប្រឡងចូលរៀន និងការប្រឡងបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្ររងសម្រាប់ការអនុវត្តនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល នៅពេលដែលពុំទាន់មានការប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិ។

**ប្រការ ៤.-** ការប្រកាសលទ្ធផលនៃការជ្រើសរើស ឬ ការប្រឡងចូលរៀន និងការប្រឡងបញ្ចប់ការសិក្សាត្រូវធ្វើនៅមណ្ឌលប្រឡងដោយមានការទទួលស្គាល់ពីតំណាងក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាដែលបានចូលរួម និងត្រូវយកលទ្ធផលដើម្បីស្នើសុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ ៥.-** ការផ្តល់សញ្ញាបត្រដល់និស្សិតដែលប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យ ចាំបាច់ត្រូវយោងលើលទ្ធផលនៃការជ្រើសរើសឬការប្រឡងចូលរៀន និងការប្រឡងបញ្ចប់ការសិក្សាដែលទទួលស្គាល់ជាផ្លូវការដោយក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា នៅពេលដែលពុំទាន់មានការប្រឡងចេញថ្នាក់ជាតិ។

**ប្រការ ៦.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសរួមនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-** អគ្គនាយកបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល អគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលមានភារកិច្ចអនុវត្តតាមប្រកាសរួមនេះឱ្យមានប្រសិទ្ធភាព ចាប់ពីពេលនេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** | **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**អ៊ឹម_សិទ្ធី** | **ម៉ម_ប៊ុនហេង**

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការប្រឡងថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ